# ដីកាការបង្រួបបង្រួមគ្រួសារឡើងវិញ

# (Family reunification order)

ព័ត៌មានសម្រាប់មនុស្សវ័យក្មេង (Information for young people)

**Khmer | ភាសាខ្មែរ**

**OFFICIAL**

ឯកសារនេះមិនមែនជាដំបូន្មានផ្នែកច្បាប់ទេ។ នេះត្រូវបានណែនាំថាអ្នកគួរស្វែងរកជំនួយពីមេធាវី ដើម្បីឆ្លើយសំណួរណាមួយដែលអ្នកអាចមាន

## មាតិកា


**រយៈពេលដែលដីកាការបង្រួបបង្រួមគ្រួសារឡើងវិញត្រូវបញ្ចប់ ..... 2**

**កន្លែងដែលអ្នកនឹងរស់នៅ ..... 2**

**ធម្មនុញ្ញសម្រាប់កុមារដែលរស់នៅក្រោមការថែទាំបណ្ដោះអាសន្ននៅក្រៅក្រុមគ្រួសារ ..... 2**

**ការជួបឪពុកម្ដាយរបស់អ្នក ..... 3**

**អ្វីខ្លះដែលបុគ្គលិកធ្វើការធ្វើ ..... 3**

**តើតុលាការអាចកែប្រែ (ផ្លាស់ប្ដូរ) ឬដកហូតវិញ (លុបចោល) ដីកាការបង្រួបបង្រួមគ្រួសារឡើងវិញបានទេ? ..... 3**

**ប្រសិនបើអ្នកមិនយល់ស្របនឹងអ្វីដែលកើតឡើងនៅតុលាការ ..... 4**

**កន្លែងដែលអ្នកអាចទទួលបានដំបូន្មានផ្នែកច្បាប់ ..... 4**

**ព័ត៌មានទំនាក់ទំនង ..... 4**


ចៅក្រមថ្នាក់ក្រោមនៅតុលាការកុមារបានចេញ**ដីកាការបង្រួបបង្រួមគ្រួសារឡើងវិញ**មួយ។ នេះដោយសារតែសុវត្ថិភាព និងការអភិវឌ្ឍន៍របស់អ្នកស្ថិតក្នុងហានិភ័យ ហើយអ្នកត្រូវការកិច្ចការពារ។

ដីកានេះមានន័យថា អ្នកនឹងត្រូវបានមើលថែដោយអ្នកថែទាំ ខណៈពេលដែលឪពុកម្ដាយរបស់អ្នកដោះស្រាយកង្វល់នានាអំពីសុវត្ថិភាព និងការអភិវឌ្ឍន៍របស់អ្នក។ គោលដៅនៃដីកានេះគឺថាអ្នកនឹងអាចត្រឡប់ទៅរស់នៅជាមួយឪពុកម្ដាយរបស់អ្នកវិញដោយសុវត្ថិភាពនាពេលអនាគត។

តុលាការអាចបានរួមបញ្ចូលលក្ខខណ្ឌមួយចំនួននៅលើដីកានោះ។ ប្រសិនបើលក្ខខណ្ឌទាក់ទងនឹងអ្នក អ្នកត្រូវធ្វើអ្វីដែលដីកានោះនិយាយ។ អ្នកអនុវត្តវិជ្ជាជីវៈកិច្ចការពារកុមាររបស់អ្នក (បុគ្គលិកធ្វើការរបស់អ្នក) នឹង៖

- ពន្យល់ពីលក្ខខណ្ឌទាំងនេះដល់អ្នក
- ជួយអ្នកឱ្យអនុវត្តតាមលក្ខខណ្ឌទាំងនោះ។

ដីកានេះមានន័យថា ក្រសួងទទួលបន្ទុកគ្រួសារ យុត្តិធម៌ និងលំនៅដ្ឋាន (ក្រសួង) អាចសម្រេចចិត្ត៖

- កន្លែងដែលអ្នកនឹងរស់នៅ
- អ្នកណានឹងមើលថែអ្នក
- សកម្មភាពប្រចាំថ្ងៃអ្វីខ្លះដែលអ្នកអាចធ្វើ។

ក្រសួង និងអ្នកថែទាំរបស់អ្នកនឹងអាចធ្វើការសម្រេចចិត្តប្រចាំថ្ងៃ និងរយៈពេលខ្លីសម្រាប់អ្នក។ ការសម្រេចចិត្តអំពីបញ្ហារយៈពេលវែងសំខាន់ៗមិនអាចធ្វើបាន ដោយគ្មានការយល់ព្រមពីឪពុកម្តាយរបស់អ្នកទេ លើកលែងតែ៖

- រឿងមួយចំនួនអំពីសុខភាពរបស់អ្នក ដែលច្បាប់អនុញ្ញាត
- ប្រសិនបើរឿងទាំងនោះទាក់ទងនឹងលក្ខខណ្ឌនានានៃដីកានោះ។

បញ្ហារយៈពេលវែងសំខាន់ៗ គឺជារឿងមួយចំនួនដូចជាកន្លែងណាដែលអ្នកទៅរៀន។

# រយៈពេលដែលដីកាការបង្រួបបង្រួមគ្រួសារឡើងវិញត្រូវបញ្ចប់

ដីកាការបង្រួបបង្រួមគ្រួសារឡើងវិញត្រូវបញ្ចប់ រហូតដល់កាលបរិច្ឆេទដែលបានសរសេរនៅលើដីកានោះដោយចៅក្រមថ្នាក់ក្រោម។

នៅពេលដីកាការបង្រួបបង្រួមគ្រួសារឡើងវិញត្រូវបញ្ចប់ តុលាការអាចបន្តវារហូតដល់ទៅ 12 ខែក្នុងមួយពេល។ តុលាការនឹងបន្តដីកាលុះត្រាតែរឿងនេះស្ថិតនៅក្នុងផលប្រយោជន៍ល្អបំផុតរបស់អ្នក។

តុលាការនឹងពិចារណា៖

- ថាតើមានការបន្តរួចហើយឬនៅ និងរយៈពេលប៉ុន្មានដែលការបន្តទាំងនោះមាន
- ប្រសិនបើឪពុកម្តាយរបស់អ្នកបានព្យាយាមទទួលបានជំនួយដែលពួកគេត្រូវការ
- ថាតើបញ្ហាផ្សេងទៀតនៅខាងក្រៅការគ្រប់គ្រងរបស់ឪពុកម្តាយអ្នក បានរារាំងពួកគេពីការថែទាំអ្នកដោយសុវត្ថិភាពឬអត់។

# កន្លែងដែលអ្នកនឹងរស់នៅ

ប្រសិនបើអ្នករស់នៅឆ្ងាយពីផ្ទះ ខណៈពេលដែលតុលាការកំពុងធ្វើការសម្រេចចិត្តរបស់ខ្លួន នោះអ្នកប្រហែលជាអាចស្នាក់នៅកន្លែងដែលអ្នកនៅ។

ប្រសិនបើអ្នកត្រូវការផ្លាស់ប្តូរទីកន្លែង ក្រសួងនឹងព្យាយាមរៀបចំឱ្យអ្នករស់នៅជាមួយអ្នកផ្សេងក្រៅពីគ្រួសាររបស់អ្នក ឬមនុស្សដែលអ្នកស្គាល់។ បើមិនដូច្នោះទេ អ្នកអាចរស់នៅជាមួយអ្នកថែទាំចិញ្ចឹមបីបាច់ ឬនៅក្នុងផ្ទះ ឬអង្គភាពដែលមានមនុស្សមកមើលថែអ្នក។

អ្នកអាចរស់នៅជាមួយនរណាម្នាក់បាន លុះត្រាតែក្រសួងវាយតម្លៃថាពួកគេសមរម្យ។

ប្រសិនបើអ្នកមានបងប្អូនប្រុសឬ ស្រីដែលត្រូវការមើលថែផងដែរ អ្នកនឹងរស់នៅជាមួយគ្នា ប្រសិនបើអាចធ្វើទៅបាន។ ពេលខ្លះ វាមិនអាចទៅរួចទេសម្រាប់បងប្អូនប្រុសស្រីរស់នៅជាមួយគ្នា។ ប្រសិនបើរឿងនោះកើតឡើង វាពិតជាសំខាន់ណាស់សម្រាប់អ្នកក្នុងការរក្សាទំនាក់ទំនងគ្នា។ អ្នកនៅតែអាចជួបគ្រួសារ និងមិត្តភក្តិរបស់អ្នក ហើយបុគ្គលិកធ្វើការរបស់អ្នកអាចជួយរៀបចំរឿងនេះបាន។

# ធម្មនុញ្ញសម្រាប់កុមារដែលរស់នៅក្រោមការថែទាំបណ្តោះអាសន្ននៅក្រៅក្រុមគ្រួសារ

បុគ្គលិកធ្វើការរបស់អ្នកនឹងធ្វើឱ្យប្រាកដថា អ្នកមានច្បាប់ចម្លងនៃ *ធម្មនុញ្ញសម្រាប់កុមារដែលរស់នៅក្រោមការថែទាំបណ្តោះអាសន្ននៅក្រៅក្រុមគ្រួសារ*។ វាពន្យល់ពីអ្វីដែលអ្នកអាចរំពឹងទុកខណៈពេលដែលអ្នករស់នៅឆ្ងាយពីផ្ទះ។

# ការជួបឪពុកម្ដាយរបស់អ្នក

វាជាការសំខាន់សម្រាប់អ្នកក្នុងការរក្សាទំនាក់ទំនងជាមួយឪពុកម្ដាយរបស់អ្នក។ បុគ្គលិកធ្វើការរបស់អ្នកនឹងជួយអ្នកធ្វើបែបនេះ។ ប្រសិនបើអ្នកមានបញ្ហាណាមួយជាមួយនឹងការទាក់ទងរបស់អ្នកជាមួយឪពុកម្ដាយរបស់អ្នក អ្នកគួរតែនិយាយជាមួយបុគ្គលិកធ្វើការរបស់អ្នក។

# អ្វីខ្លះដែលបុគ្គលិកធ្វើការធ្វើ

បុគ្គលិកធ្វើការរបស់អ្នកនឹង៖

- ពិភាក្សាជាមួយអ្នកអំពីបញ្ហានានាដែលនាំឱ្យតុលាការធ្វើដីកានោះ
- ធ្វើការជាមួយអ្នក និងគ្រួសាររបស់អ្នកដើម្បីអនុវត្តផែនការករណីរបស់អ្នកឱ្យដំណើរការ
- ពិនិត្យមើលផែនការករណីពីពេលមួយទៅពេលមួយ និងចូលរួមជាមួយអ្នកនៅពេលដែលពួកគេពិនិត្យមើលវា
- ជួយអ្នកឱ្យគិតអំពីរបៀបដែលអ្វីៗកំពុងដំណើរការ ជាមួយនឹងការដោះស្រាយបញ្ហានានាដែលនាំឱ្យមានដីកានោះ។ នេះគឺដើម្បីឱ្យអ្នកអាចត្រឡប់ទៅផ្ទះវិញបានឆាប់ តាមដែលអាចធ្វើទៅបាន
- និយាយជាមួយអ្នកអំពីការផ្លាស់ប្ដូរនានាដែលត្រូវកើតឡើងសម្រាប់អ្នក ដើម្បីត្រឡប់ទៅផ្ទះវិញដោយសុវត្ថិភាព
- និយាយជាមួយអ្នកអំពីប្រភេទនៃការគាំទ្រ និងសេវាកម្មនានាដែលអ្នកត្រូវការដើម្បីត្រឡប់ទៅផ្ទះវិញ
- ជួយឪពុកម្ដាយរបស់អ្នកជាមួយនឹងការផ្លាស់ប្ដូរនានាដែលពួកគេចង់ធ្វើ ក៏ដូចជាការស្វែងរកសេវាកម្មឯកទេសដើម្បីជួយពួកគេ។

និយាយជាមួយបុគ្គលិកធ្វើការរបស់អ្នកអំពីបញ្ហា ឬកង្វល់របស់អ្នក។ វាគឺជាការងាររបស់ពួកគេក្នុងការជួយអ្នក។ អ្នកអាចមានអារម្មណ៍ច្របូកច្របល់ ឬភ័យខ្លាច ធូរស្រាល ខឹង ឬសោកសៅ ឬអ្វីមួយផ្សេងទៀត។
ស្វែងរកមនុស្សពេញវ័យម្នាក់ដែលអ្នកមានអារម្មណ៍ថាមានសុវត្ថិភាពក្នុងការនិយាយអំពីអារម្មណ៍របស់អ្នក។ នេះអាចជាអ្នកថែទាំរបស់អ្នក ឬបុគ្គលិកធ្វើការរបស់អ្នក ឬអ្នកណាម្នាក់ផ្សេងទៀត។ ប្រសិនបើអ្នកត្រូវការជំនួយអំពីអារម្មណ៍របស់អ្នក អ្នកត្រូវប្រាប់អ្នកថែទាំ ឬបុគ្គលិកធ្វើការរបស់អ្នកឱ្យដឹង។

# តើតុលាការអាចកែប្រែ (ផ្លាស់ប្ដូរ) ឬដកហូតវិញ (លុបចោល) ដីកាការបង្រួបបង្រួមគ្រួសារឡើងវិញបានទេ?

អ្នកអាចដាក់ពាក្យទៅតុលាការកុមារដើម្បី៖

- កែប្រែ (ផ្លាស់ប្ដូរ) លក្ខខណ្ឌណាមួយនៃដីកានោះនៅពេលណាក៏បាន។ ឪពុកម្ដាយរបស់អ្នក ឬបុគ្គលិកធ្វើការក៏អាចធ្វើបែបនេះបានដែរ។
- ដកហូតវិញ (លុបចោល) ដីកានៅពេលណាក៏បាន ប្រសិនបើអ្នកគិតថាស្ថានភាពបានផ្លាស់ប្ដូរ ហើយអ្នកលែងមានហានិភ័យទៀតហើយ។ ឪពុកម្ដាយរបស់អ្នក ឬបុគ្គលិកធ្វើការក៏អាចធ្វើបែបនេះបានដែរ។

ប្រាប់បុគ្គលិកធ្វើការរបស់អ្នក ឬទាក់ទងមេធាវីរបស់អ្នក ប្រសិនបើអ្នកចង់ដាក់ពាក្យស្នើសុំកែប្រែ ឬដកហូតដីកានោះវិញ។

ក្រសួងអាចប្រាប់ឪពុកម្ដាយរបស់អ្នកឱ្យមើលថែអ្នកម្ដងទៀត ប្រសិនបើវាស្ថិតនៅក្នុងផលប្រយោជន៍ល្អបំផុតរបស់អ្នក។ ដីការបស់អ្នកនឹងក្លាយជាដីកាការក្សាការពារគ្រួសារ។

ពួកគេនឹងនិយាយជាមួយអ្នកជាមុនសិន ហើយស្តាប់អ្វីដែលអ្នកគិតអំពីការត្រឡប់ទៅផ្ទះវិញ មុនពេលពួកគេសម្រេចចិត្ត។ រឿងនេះនឹងកើតឡើងលុះត្រាតែមាន៖

- ពេលវេលាគ្រប់គ្រាន់មុនពេលដីកាបម្រុងនឹងបញ្ចប់ ហើយ
- មិនមានពាក្យសុំតុលាការផ្សេងទៀតសម្រាប់អ្នកទេ។

ប្រសិនបើវាលែងស្ថិតនៅក្នុងផលប្រយោជន៍ល្អបំផុតរបស់អ្នកក្នុងការព្យាយាមត្រឡប់ទៅផ្ទះវិញ ក្រសួងអាចដាក់ពាក្យទៅតុលាការសម្រាប់ដីកាផ្សេងមួយ។ ប្រសិនបើតុលាការយល់ព្រម ក្រសួងនឹងរៀបចំអ្នកផ្សេងឱ្យមើលថែអ្នករហូតដល់អ្នកធំឡើង។

# ប្រសិនបើអ្នកមិនយល់ស្របនឹងអ្វីដែលកើតឡើងនៅតុលាការ

ប្រសិនបើអ្នកគិតថាការសម្រេចរបស់តុលាការកុមារមិនយុត្តិធម៌ អ្នកមានសិទ្ធិប្តឹងឧទ្ធរណ៍ទៅតុលាការកំពូល។ អ្នកមានរយៈពេល 28 ថ្ងៃដើម្បីប្តឹងឧទ្ធរណ៍បន្ទាប់ពីតុលាការកុមារចេញដីកា។

ទម្រង់បែបបទប្តឹងឧទ្ធរណ៍អាចរកបានពី៖

- តុលាការកុមារណាមួយ
- តុលាការចៅក្រមថ្នាក់ក្រោមណាមួយ
- តុលាការខោនធី (County Court)។

វាជាការល្អបំផុតក្នុងការស្វែងរកជំនួយពីមេធាវី ប្រសិនបើអ្នកសម្រេចចិត្តប្តឹងឧទ្ធរណ៍លើការសម្រេចរបស់តុលាការកុមារ។

ប្រសិនបើអ្នកចង់ដឹងបន្ថែម សូមសួរបុគ្គលិកធ្វើការរបស់អ្នក ឬមេធាវីដែលបានតំណាងអ្នកនៅតុលាការ។

# កន្លែងដែលអ្នកអាចទទួលបានដំបូន្មានផ្នែកច្បាប់

អ្នកអាចទទួលបានដំបូន្មានផ្នែកច្បាប់ពី៖

- មេធាវីដែលបានតំណាងអ្នកនៅតុលាការ
- មេធាវីនៅតាមមូលដ្ឋាន (ដែលមានរាយក្នុងបញ្ជីមេធាវីនៅក្នុងសៀវភៅចុះបញ្ជីពាណិជ្ជកម្មទំព័រពណ៌លឿង)
- ជំនួយផ្នែកច្បាប់រដ្ឋវិចថូរៀ (Victoria Legal Aid), ទីក្រុងមែលប៊ន ទូរសព្ទ 1300 792 387
- វិទ្យាស្ថានច្បាប់រដ្ឋវិចថូរៀ ទូរសព្ទ (03) 9607 9311
- សេវាកម្មផ្នែកច្បាប់ជនជាតិដើម Aboriginal រដ្ឋវិចថូរៀ (Victorian Aboriginal Legal Service) Co-op Ltd ទូរសព្ទ 1800 064 865
- Djirra ទូរសព្ទ 1800 105 303
- សេវាកម្មផ្នែកច្បាប់សហគមន៍នៅតាមមូលដ្ឋាន។

# ព័ត៌មានទំនាក់ទំនង

ឈ្មោះបុគ្គលិកកិច្ចការពារកុមាររបស់អ្នក៖ ______________________________

លេខទូរសព្ទទំនាក់ទំនងបុគ្គលិកកិច្ចការពារកុមាររបស់អ្នក៖ ______________________________

ការិយាល័យនៃក្រសួងទទួលបន្ទុកគ្រួសារ យុត្តិធម៌ និងលំនៅដ្ឋានរបស់ពួកគេ៖

______________________________

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងការិយាល័យនៃក្រសួងទទួលបន្ទុកគ្រួសារ យុត្តិធម៌ និងលំនៅដ្ឋានក្នុងតំបន់របស់អ្នក។

ទាក់ទងមកយើងដើម្បីទទួលបានឯកសារនេះជាទម្រង់ផ្សេងទៀត។ អ៊ីមែល
CpManual@dffh.vic.gov.au

បានអនុញ្ញាត និងបោះពុម្ពផ្សាយដោយរដ្ឋាភិបាលរដ្ឋវិចថូរៀ 1 Treasury Place, Melbourne។
© រដ្ឋវិចថូរៀ ប្រទេសអូស្ត្រាលី ក្រសួងទទួលបន្ទុកគ្រួសារ យុត្តិធម៌ និងលំនៅឋាន ខែឧសភា ឆ្នាំ 2026។
ISBN 978-1-76171-138-1 (pdf/online/MS word)
អាចរកបាននៅសៀវភៅណែនាំស្តីពីកិច្ចការពារកុមារ – ដីកាការបង្រួបបង្រួមគ្រួសារឡើងវិញ
https://www.cpmanual.vic.gov.au/advice-and-protocols/information-sheets/orders/family-reunification-order
2604564